Khmer | ភាសាខ្មែរ

Improvements to the NDIS

# ការកែលម្អចំពោះ NDIS

យើងកំពុងតែធ្វើការកែលម្អលើរបៀបដែលយើងផ្តល់ NDIS។

មានការផ្លាស់ប្តូរមួយចំនួនលើ៖

- របៀបដែលអ្នកត្រូវដាក់ពាក្យសុំ NDIS។
- របៀបដែលយើងបង្កើតផែនការរបស់អ្នក។
- របៀបដែលយើងធ្វើការផ្លាស់ប្តូរមួយចំនួនចំពោះផែនការរបស់អ្នក។
- ការកត់ត្រាអ្នកផ្តល់សេវានៅក្នុងផែនការរបស់អ្នក។

យើងមិនផ្លាស់ប្តូរបទបញ្ញត្តិ ឬរបៀបដែល NDIS ដំណើរការនោះទេ។ មិនមានការផ្លាស់ប្តូរពីរបៀបដែលយើងធ្វើការសម្រេចចិត្ត និងអ្វីដែលយើងអាចផ្តល់មូលនិធិនៅក្រោម NDIS នោះទេ។

ដើម្បីជួយយើងឱ្យផ្តល់លទ្ធផលបានប្រសើរឡើង សម្រាប់អ្នកចូលរួមនានានៅពេលនេះ និងក្នុងពេលអនាគត យើងបានបង្កើតប្រព័ន្ធកុំព្យូទ័រថ្មី និងកែលម្អរបៀបដែលយើងធ្វើការ។ យើងបានចាប់ផ្តើមណែនាំប្រព័ន្ធកុំព្យូទ័រថ្មីរបស់យើង និងការកែលម្អដំណើរការនៅទូទាំងប្រទេសអូស្ត្រាលី ។

មិនមានអ្វីដែលអ្នកដាក់ពាក្យសុំ ឬអ្នកចូលរួម ឬអ្នកគាំទ្ររបស់ពួកគេត្រូវធ្វើនៅពេលនេះទេ។ នៅពេលអ្នកមកដល់ជំហានបន្ទាប់នៃដំណើរ NDIS របស់អ្នក យើងនឹងធ្វើការជាមួយអ្នកដើម្បីធានាថាអ្នកមានការគាំទ្រ និងព័ត៌មានដែលអ្នកត្រូវការ។

រាល់ពេលដែលយើងធ្វើការជាមួយគ្នា យើងនឹងប្រាប់អ្នកពីប្រព័ន្ធកុំព្យូទ័រមួយណាដែលផែនការរបស់អ្នកស្ថិតនៅ។ ធ្វើដូចនេះដើម្បីឱ្យអ្នកអាចមានការជឿជាក់ពីអ្វីដែលអ្នកអាចរំពឹងទុក និងអាចចែករំលែកព័ត៌មាននេះជាមួយមនុស្សដែលសំខាន់សម្រាប់អ្នក ដូចជាអ្នកគាំទ្រ ឬអ្នកផ្តល់សេវារបស់អ្នក។

អ្នកអាចអានបន្ថែមអំពីការកែលម្អរបស់យើងនៅលើ គេហទំព័រ របស់យើង។

## បង្កើតការភ្ជាប់ទំនាក់ទំនង

NDIS អាចជួយមនុស្សដែលមានពិការភាពបាន សូម្បីតែពួកគេមិនមែនជាអ្នកចូលរួមជាមួយ NDIS ក៏ដោយ។

ប្រសិនបើអ្នកមានអាយុចន្លោះពី 9 ឆ្នាំ និង 64 ឆ្នាំ យើងអាចភ្ជាប់អ្នកទៅនឹងសេវាកម្ម និងការគាំទ្រនានាដែលមាននៅក្នុងសហគមន៍របស់អ្នក។ យើងហៅការភ្ជាប់ទំនាក់ទំនងនេះថាការភ្ជាប់ទំនាក់ទំនងសហគមន៍។

ប្រសិនបើអ្នកត្រូវការជំនួយគាំទ្រសម្រាប់កូនរបស់អ្នកដែលមានអាយុក្រោម 9 ឆ្នាំ យើងអាចផ្តល់ការភ្ជាប់ទំនាក់ទំនងបានមុនបាន។ ប្រសិនបើអ្នកមានអាយុ 65 ឆ្នាំ ឬអាយុលើសនេះ យើងអាចផ្តល់ព័ត៌មានដល់អ្នកស្តីពីសេវាថែទាំមនុស្សចាស់ ដែលអាចជួយគាំទ្រអ្នកបាន។

ដើម្បីទទួលបានការភ្ជាប់ទំនាក់ទំនងសហគមន៍ ឬការភ្ជាប់ទំនាក់ទំនងបានមុន អ្នកអាច៖

- និយាយជាមួយអ្នកណាម្នាក់នៅឯ ការិយាល័យ NDIS។
- សូមហៅទូរសព្ទមកយើងតាមលេខ 1800 800 110។
- សូមហៅទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ តាមលេខ 131 450 ហើយស្នើសុំនិយាយទៅ NDIS។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល ការបង្កើតការភ្ជាប់ទំនាក់ទំនង (making connections)។

# ការដាក់ពាក្យសុំ NDIS

របៀបដែលអ្នកដាក់ពាក្យសុំ NDIS នឹងផ្លាស់ប្តូរ។

ប្រសិនបើអ្នកមានសិទ្ធិទទួលបាន NDIS យើងនឹងជួយអ្នកដាក់ពាក្យសុំ NDIS។

ដើម្បីដាក់ពាក្យសុំ NDIS, អ្នកនឹងត្រូវការ ‘my NDIS contact’ (`ទំនាក់ទំនង NDIS របស់ខ្ញុំ)។ my NDIS contact របស់អ្នក គឺជាទំនាក់ទំនងសំខាន់សម្រាប់អ្នក និងគ្រួសាររបស់អ្នកនៅក្នុង NDIS។

ទំនាក់ទំនងទាំងនោះនឹង៖

- ផ្តល់ឱ្យអ្នកនូវព័ត៌មានអំពី NDIS។
- ជួយអ្នកឱ្យយល់ដឹងថាតើការគាំទ្រអ្វីខ្លះដែលអ្នកអាចទទួលបាន។
- ជួយគាំទ្រអ្នកដើម្បីដាក់ពាក្យសុំ NDIS។

my NDIS contact របស់អ្នក អាចជាដៃគូ NDIS ឬសមាជិកបុគ្គលិកនៃទីភ្នាក់ងារធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIA)។

ដៃគូ NDIS មានដូចជា៖

- ដៃគូកុមារតូចៗ ដែលអាចជួយកុមារអាយុក្រោម 9 ឆ្នាំ។
- អ្នកសម្របសម្រួលនៅតំបន់មូលដ្ឋាន ដែលជួយមនុស្សមានពិការភាពអាយុពី 9-64 ឆ្នាំ។

my NDIS contact របស់អ្នកនឹង ជាមនុស្សនៅឯ NDIA ប្រសិនបើ៖

- អ្នករស់នៅក្នុងតំបន់ដាច់ស្រយាលនៃប្រទេសអូស្ត្រាលី។
- មានតម្រូវការគាំទ្រដ៏ស្មុគស្មាញ។
- ជាមនុស្សវ័យក្មេងដែលស្ថិតក្នុងការថែទាំមនុស្សចាស់តាមលំនៅដ្ឋាន។
- ស្ថិតនៅក្នុងមន្ទីរពេទ្យ ឬទីកន្លែងយុត្តិធម៌។

ក្រោយអ្នកដាក់ពាក្យសុំ NDIS, យើងនឹងទាក់ទងអ្នកក្នុងរយៈពេល 21 ថ្ងៃ ដើម្បីប្រាប់ឱ្យអ្នកដឹងអំពីសេចក្តីសម្រេចរបស់យើង។ យើងក៏អាចស្នើសុំព័ត៌មានបន្ថែមពីអ្នកផងដែរ។

ប្រសិនបើអ្នកមានសិទ្ធិទទួល អ្នកនឹងក្លាយជាអ្នកចូលរួមជាមួយ NDIS។ យើងនឹងប្រើប្រាស់ព័ត៌មានដែលអ្នកបានចែករំលែកនៅក្នុងពាក្យសុំរបស់អ្នក ដើម្បីបង្កើតផែនការ NDIS ដំបូងរបស់អ្នក។

ប្រសិនបើអ្នកមិនមានសិទ្ធិទទួលទេ យើងនឹងពន្យល់ពីមូលហេតុ។ ដៃគូ NDIS របស់អ្នកនឹងជួយអ្នកឱ្យភ្ជាប់ទំនាក់ទំនងជាមួយនឹងជំនួយគាំទ្រនានាដែលមាននៅក្នុងសហគមន៍របស់អ្នក។

ដើម្បីបង្កើតការភ្ជាប់ទំនាក់ទំនងជាមួយសេវាកម្ម និងជំនួយគាំទ្រនានាដែលមាននៅក្នុងសហគមន៍របស់អ្នក ឬដើម្បីដាក់ពាក្យសុំ NDIS អ្នកអាច៖

- និយាយជាមួយអ្នកណាម្នាក់នៅ ការិយាល័យ NDIS។
- សូមហៅទូរសព្ទមកយើងតាមលេខ 1800 800 110។
- សូមហៅទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ តាមលេខ 131 450 ហើយស្នើសុំនិយាយទៅ NDIS។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល ដាក់ពាក្យសុំ NDIS។

## ការបង្កើតផែនការរបស់អ្នក

នៅពេលអ្នកក្លាយជាអ្នកចូលរួមជាមួយ NDIS អ្នកនឹងទទួលបានផែនការ NDIS មួយ។

ផែនការ NDIS គឺជាឯកសារមួយដែលមានព័ត៌មានអំពី៖

- អ្នក និងគោលដៅរបស់អ្នក។
- ការគាំទ្រដែលអ្នកត្រូវការ។
- អ្វីដែលជាជំនួយគាំទ្រ NDIS នឹងបង់ឱ្យ។

អ្នកនឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុង កិច្ចប្រជុំរៀបចំផែនការ មួយជាមួយអ្នករៀបចំផែនការនៃ NDIA ដែលបានបង្កើតផែនការរបស់អ្នក។

អ្នករៀបចំផែនការនៃ NDIA គឺជាមនុស្សម្នាក់ដែល៖

- ធ្វើការនៅ NDIA។
- បង្កើតផែនការ NDIS ថ្មីៗ។
- ផ្លាស់ប្តូរផែនការ NDIS។
- បង្កើតថវិកាផែនការ NDIS របស់អ្នក។

នៅឯកិច្ចប្រជុំរៀបចំផែនការរបស់អ្នក អ្នករៀបចំផែនការនៃ NDIA របស់អ្នកនឹងនិយាយជាមួយអ្នកអំពី៖

- ថវិកាផែនការ និងការគាំទ្រនានារបស់អ្នក។
- ការសម្រេចចិត្តដែលពួកគេបានធ្វើអំពីផែនការរបស់អ្នក។
- របៀបដែលអ្នកចង់គ្រប់គ្រងផែនការរបស់អ្នក។
- ការកត់ត្រាអ្នកផ្តល់សេវាសម្រាប់ផែនការរបស់អ្នក។
- ការផ្លាស់ប្តូរណាមួយដែលអ្នកគិតថាផែនការរបស់អ្នកត្រូវការ។

យើងនឹងផ្ញើច្បាប់ចម្លងនៃផែនការ NDIS របស់អ្នកទៅអ្នក។ អ្នកអាចប្រើផតថលអ្នកចូលរួម NDIS របស់ខ្ញុំ (NDIS participant portal) និងកម្មវិធី NDIS របស់ខ្ញុំ (my NDIS app) ដើម្បីមើលផែនការរបស់អ្នក។

ប្រសិនបើអ្នកមិនមានផែនការនៅក្នុងប្រព័ន្ធកុំព្យូទ័រថ្មីរបស់យើងទេ អ្នកគួរតែបន្តប្រើប្រាស់ផតថលអ្នកចូលរួម Myplace ដើម្បីធ្វើការទាមទារប្រាក់ឧបត្ថម្ភ។

ទំនាក់ទំនង my NDIS contact របស់អ្នក គឺជាមនុស្សល្អបំផុតដើម្បីនិយាយជាមួយ ប្រសិនបើអ្នក៖

- មានសំណួរនានា។
- អ្នកត្រូវការជំនួយគាំទ្រ នៅពេលអ្នកនិយាយជាមួយ NDIS។

អ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងរបស់ពួកគេនៅក្នុងផែនការរបស់អ្នក។

ប្រសិនបើអ្នកមានថវិកានៅក្នុងផែនការរបស់អ្នកសម្រាប់ការសម្របសម្រួលការគាំទ្រ ឬសេវាកម្មគ្រូបង្វឹកស្តារនីតិសម្បទា អ្នកអាចទទួលបានជំនួយក្នុងការប្រើប្រាស់ផែនការរបស់អ្នកពី៖

- អ្នកសម្របសម្រួលការគាំទ្រ – នរណាម្នាក់ដែលជួយអ្នកក្នុងការរៀបចំផែនការ និងប្រើប្រាស់ការគាំទ្ររបស់អ្នក។
- គ្រូបង្វឹកស្តារនីតិសម្បទា – អ្នកណាម្នាក់ដែលគាំទ្រអ្នកជាមួយនឹងសុខភាពផ្លូវចិត្តរបស់អ្នក។

បន្ទាប់ពីអ្នកទទួលបានផែនការ NDIS របស់អ្នកហើយ my NDIS contact របស់អ្នកនឹងផ្តល់ជូននូវ កិច្ចប្រជុំអនុវត្តផែនការ ដើម្បីជួយអ្នកប្រើប្រាស់ផែនការរបស់អ្នក។

my NDIS contact របស់អ្នកនឹង ពិនិត្យមើល ជាមួយអ្នក ម្តងក្នុងមួយឆ្នាំ ដើម្បីសួរអ្នកថាតើអ្នកដំណើរការដូចម្តេចហើយជាមួយនឹងផែនការរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល ការយល់ដឹងអំពីផែនការរបស់អ្នក និង ការប្រើប្រាស់ផ្នែកផែនការរបស់អ្នក នៃគេហទំព័ររបស់យើង។

## ការផ្លាស់ប្តូរផែនការរបស់អ្នក

ប្រសិនបើអ្នកមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់អ្នក ដែលមានន័យថាអ្នកត្រូវការការគាំទ្រច្រើនឡើងតិចជាង ឬការគាំទ្រផ្សេង អ្នកអាចស្នើសុំផ្លាស់ប្តូរផែនការរបស់អ្នកនៅពេលណាក៏បាន។

មានវិធីពីរយ៉ាងដើម្បីផ្លាស់ប្តូរផែនការរបស់អ្នក – ការប្រែប្រួលផែនការ ឬការវាយតម្លៃផែនការឡើងវិញ។

ការប្រែប្រួលផែនការ គឺជាការផ្លាស់ប្តូរតិចតួចមួយចំពោះផែនការបច្ចុប្បន្នរបស់អ្នក។ ការវាយតម្លៃផែនការឡើងវិញគឺនៅពេលដែលយើងជំនួសផែនការរបស់អ្នកដោយផែនការថ្មីមួយ។

my NDIS contact របស់អ្នក អ្នកសម្របសម្រួលការគាំទ្រ ឬគ្រូបង្វឹកស្តារនីតិសម្បទាអាចពន្យល់អំពីព័ត៌មាន និងភស្តុតាងដែលយើងត្រូវការដើម្បីសម្រេចចិត្តអំពីការផ្លាស់ប្តូរផែនការរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល ការផ្លាស់ប្តូរផែនការរបស់អ្នក។

## អ្នកផ្តល់សេវារបស់ខ្ញុំ

ផែនការ NDIS ថ្មីរបស់អ្នកនឹងមិនមាន ការកក់សេវាកម្មទេ។

ប្រសិនបើអ្នកមានការផ្តល់មូលនិធិដែលគ្រប់គ្រងដោយ NDIA កន្លែងស្នាក់នៅឯកទេសសម្រាប់ជនពិការ ការគាំទ្រតាមលំនៅដ្ឋាន និងការរស់នៅ ឬការគាំទ្រអាកប្បកិរិយានៅក្នុងផែនការរបស់អ្នក អ្នកត្រូវប្រាប់យើងថាអ្នកផ្តល់សេវាកម្មមួយណាដែលផ្តល់ការគាំទ្ររបស់អ្នក ដើម្បីឱ្យយើងអាចកត់ត្រាវានៅក្នុងផែនការរបស់អ្នក។

យើងហៅអ្នកផ្តល់សេវាដែលបានកត់ត្រានៅក្នុងផែនការរបស់អ្នកថា "អ្នកផ្តល់សេវារបស់ខ្ញុំ"។ អ្នកផ្តល់សេវានៅក្នុងផែនការរបស់អ្នកអាចធ្វើការទាមទារទល់នឹងផែនការ NDIS របស់អ្នក នៅពេលពួកគេផ្តល់ការគាំទ្ររបស់អ្នក។

ការកត់ត្រាអ្នកផ្តល់សេវានៅក្នុងផែនការរបស់អ្នក មានន័យថាយើងមិនចាំបាច់ពិនិត្យជាមួយអ្នក មុនពេលយើងបង់ប្រាក់ឱ្យពួកគេទេ។

អ្នកអាចធ្វើបច្ចុប្បន្នភាព ឬផ្លាស់ប្តូរ my providers របស់អ្នក (អ្នកផ្តល់សេវារបស់ខ្ញុំ) នៅពេលណាក៏បាន។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល my providers (អ្នកផ្តល់សេវារបស់ខ្ញុំ)។

### ការទាក់ទង NDIS

សម្រាប់អ្នកបកប្រែភាសាសរសេរ ឬអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ សូមទូរសព្ទទៅលេខ 131 450 ហើយស្នើសុំនិយាយជាមួយ NDIS។

my NDIS contact របស់អ្នក ក៏អាចចាត់ចែងអ្នកបកប្រែផ្ទាល់មាត់ផងដែរនៅពេលពួកគេជួប ឬនិយាយជាមួយអ្នក។

អ្នកផ្ដល់សេវារបស់អ្នកក៏អាចចាត់ចែងអ្នកបកប្រែផ្ទាល់មាត់ផងដែរ នៅពេលអ្នកជួប ឬនិយាយជាមួយពួកគេ ។

អ្នកក៏អាចទៅកាន់ការិយាល័យ NDIS និងស្នើសុំនិយាយជាមួយអ្នកបកប្រែផ្ទាល់មាត់បានផងដែរ។ រកមើលទីកន្លែងការិយាល័យ NDIS នៅជិតអ្នកបំផុតនៅលើ គេហទំព័រ NDIS។

**ងាយស្រួលអាន (Easy Read)**
ព័ត៌មានអំពី NDIS ក៏ត្រូវបានបកប្រែជាសណ្ឋានងាយស្រួលអាន (Easy Read) ផងដែរ។ មនុស្សជាច្រើនយល់ថាមាតិកាងាយស្រួលអានមានប្រយោជន៍ រួមទាំងអ្នកដែលពិបាកអានភាសាអង់គ្លេសផងដែរ។

សូមចូលទៅកាន់ ទំព័រកូនសៀវភៅ និងសន្លឹកព័ត៌មានស្ដីពី NDIS ដើម្បីមើលមាតិកាក្នុងសណ្ឋានងាយស្រួលអាន (Easy Read)។